



ដោយប្រធាន រ័សុល អិម ណិលសុន

# ការស្ដារឡើងវិញ គឺសម្រាប់ប្អូន។

តើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបាន ស្ដារឡើងវិញ នៅលើផែនដី មានអត្ថន័យយ៉ាងណាចំពោះប្អូន ?

វាមានន័យថា គ្រួសាររបស់ប្អូនអាចត្រូវបានផ្សារភ្ជាប់ជាមួយគ្នាជានិរន្តរ៍ ! វាមានន័យថា នៅពេលប្អូនទទួលបុណ្យជ្រមុជទឹក ហើយបានបញ្ជាក់ជាសមាជិកនៃសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ នោះព្រះវិញ្ញាណបរិសុទ្ធអាចនឹងគង់នៅជាមួយប្អូនជានិច្ច ! វាមានន័យថា អំណាចបព្វជិតភាពរបស់ព្រះអាចប្រទានពរដល់ប្អូន ពេលប្អូនធ្វើសេចក្ដីសញ្ញាជាមួយនឹងទ្រង់ ហើយរក្សាសេចក្ដីសញ្ញាទាំងនោះ។

យ៉ូសែប ស្ម៊ីធ ជាព្យាការីរបស់ព្រះ គឺជាព្យាការី *របស់ប្អូន* ។ លោកគឺជាព្យាការីដំបូងគេបង្អស់នៃសាសនាចក្រដែលបានស្ដារឡើងវិញ ។ វិវរណៈ បន្តចាក់ស្រោចមកពីព្រះអម្ចាស់អំឡុងដំណើរការបន្តបន្ទាប់នៃការស្ដារឡើងវិញនេះ ។

ព្រះមានព្រះជន្មរស់ ! ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ! សាសនាចក្ររបស់ទ្រង់ត្រូវបានស្ដារឡើងវិញ ! ទ្រង់និងព្រះវរបិតាសួគ៌របស់យើង កំពុងទតមើលយើង ។●

*បានដកស្រង់ចេញពី « ចូរស្ដាប់តាមទ្រង់ចុះ »* Liahona *ខែឧសភា ឆ្នាំ២០២០ ទំព័រ ៨៨–៩២ ។*

## ផ្ញើរូបភាពនេះត្រឡប់មកសភាពដើមវិញ

សូមទៅកាន់ទំព័រ ៦ ហើយអានអំពីអត្ថន័យនៃ *ការស្ដារឡើងវិញ* ។ ក្រោយមកព្យាយាមធ្វើរូបភាពនេះត្រឡប់មកដូចសភាពដើមវិញ ដោយការគូរនូវផ្នែកដែលបានបាត់ !



### សាសនាចក្រដែលបានស្ដារឡើងវិញ

នៅពេលសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានស្ដារឡើងវិញ យ៉ូសែប ស្ម៊ីធ បានទទួលអំណាចបព្វជិតភាពដែលបានបាត់បង់ ។ លោកក៏បានរៀនអំពីសេចក្ដីពិតមកពីព្រះ ដែលជាសេចក្ដីពិតដែលបានបាត់បង់ផងដែរ ។ យើងបន្តទទួលបានពន្លឺ និងសេចក្ដីពិតពីព្រះបន្ថែមទៀតនាសព្វថ្ងៃនេះ ។ ការស្ដារឡើងវិញនៅតែបន្ត !